

# ដីនៃក្តីសង្ឃឹម៖ ដំណើរជីវិតរបស់អ្នកស្រី ពុតហៃ និងលោក ដា

អ្នកស្រី អឿង ពុតហៃ អាយុ៣០ឆ្នាំ បានរៀបរាប់អំពីបញ្ហាលំបាកក្នុងជីវភាពរស់នៅកាលពី ១០ឆ្នាំកន្លងទៅ នៅពេលដែលអ្នកស្រី បម្រើការជាកម្មកររោងចក្រ។ ដោយសារតែគ្មានដី អ្នកស្រី ពុតហៃ និងស្វាមីរបស់គាត់ មឿក ដា បានសម្រេចចិត្តធ្វើចំណាកស្រុកទៅកាន់រាជធានីភ្នំពេញដើម្បីស្វែងរកការងារធ្វើ ក្រោយពីពួកគាត់បានរៀបការនៅឆ្នាំ ២០០៥ ក្នុងគោលបំណងដើម្បីរកប្រាក់ទិញដីមួយឡូត៍សម្រាប់រស់នៅនិងធ្វើកសិកម្ម។ អ្នកស្រី ពុតហៃ ទទួលបានការងារជាកម្មករកាត់ដេរ នៅរោងចក្រកាត់ដេរមួយ និងទទួលបានប្រាក់បៀវត្សរ៍ប្រចាំខែ ៥០ដុល្លារ ចំណែកឯ ស្វាមីរបស់គាត់ ធ្វើជាកម្មករសំណង់ និងអាចរកប្រាក់ចំណូលមិនទៀងទាត់បានប្រហែល ៥ដុល្លារក្នុងមួយថ្ងៃ។

ប៉ុន្តែ ទោះបីជាពួកគាត់ទាំងពីរខំប្រឹងធ្វើការអស់រយៈពេលបីឆ្នាំក៏ដោយ ក៏ពួកគាត់មិនមានសល់ប្រាក់ដែរ ព្រោះចំណូលដែលរកបាន ត្រូវចំណាយលើថ្លៃជួលផ្ទះ ម្ហូបអាហារ ទឹកភ្លើង ព្យាបាលជំងឺ និងចំណាយផ្សេងៗទៀត។ ទីបំផុត នៅឆ្នាំ២០០៨ អ្នកស្រី ពុធហៃ និងស្វាមី បានសម្រេចចិត្តវិលត្រឡប់ទៅរស់នៅជាមួយម្តាយរបស់គាត់វិញនៅឯភូមិថ្មកែវ ឃុំពាម ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។ ជាភ័ព្វសំណាងល្អ នៅចុងឆ្នាំ២០០៨ ពួកគាត់ទាំងពីរបានទទួលដំណឹងពីប្រធានភូមិថា មានអង្គការមិនមែនរដ្ឋាភិបាលមួយកំពុងអនុវត្តអនុគម្រោងដីសម្បទានសង្គមកិច្ច ក្រោមក្របខ័ណ្ឌគម្រោងឡាសិត ២ នៅក្នុងស្រុកសាមគ្គីមានជ័យ ដែលគម្រោងនោះ ផ្តល់ដីលំនៅឋានទំហំ ៣០ម x ៤០ម និងដីកសិកម្មទំហំមួយហិកតាជូនគ្រួសារក្រីក្រគ្មានដីនិងខ្វះដីសម្រាប់រស់នៅនិងធ្វើកសិកម្ម។

បន្ទាប់ពីឆ្លងកាត់ដំណើរការជ្រើសរើសអ្នកទទួលដីប្រកបដោយភាពត្រឹមត្រូវ និងតម្លាភាព គ្រួសារអ្នកស្រី ពុតហៃ បានទទួលដីលំនៅឋានមួយឡូត៍ និងដីកសិកម្មមួយឡូត៍ ស្ថិតនៅតំបន់ដីសម្បទានសង្គមកិច្ចក្នុងភូមិខ្សាច់ស ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ។ នៅឆ្នាំ ២០១២ គ្រួសារអ្នកស្រី ពុតហៃ បានទៅតាំងទីលំនៅនៅលើដីលំនៅឋានថ្មី និងបានចាប់ផ្តើមកសាងជីវិតថ្មីនៅទីនោះរហូតមកដល់បច្ចុប្បន្ន។

អ្នកស្រីពុតហៃបាននឹកគិតដល់អារម្មណ៍ដ៏រំភើបរបស់គាត់ កាលពី១០ឆ្នាំ កន្លងទៅថា៖ «ខ្ញុំនៅចងចាំច្បាស់ថាកាលនោះ ខ្ញុំមានក្តីរំភើបយ៉ាងខ្លាំងរកអ្វីប្រៀបមិនបានទេ នៅពេលដែលដឹងថា ខ្ញុំទទួលបានដី ហើយភ្លាមនោះពួកខ្ញុំទាំងពីរ បានគិតថា តើត្រូវធ្វើអ្វីខ្លះនៅលើដីនោះ។»

ដោយក្តីរីករាយនិងភាពជឿជាក់ អ្នកស្រី ពុតហៃ និងស្វាមី បានសាងសង់ផ្ទះតូចមួយនៅលើដីលំនៅឋានដើម្បីរស់នៅ។ នៅឆ្នាំដំបូង ពួកគាត់ទាំងពីរ បានដាំបន្លែ និងចិញ្ចឹមមាន់ នៅលើដីដែលនៅសល់ និងនៅក្នុងឆ្នាំបន្តបន្ទាប់ទៀត ពួកគាត់បានបង្កើនការដាំដុះដំណាំ ដោយបានដាំឪឡឹក និងពោតនៅលើដីកសិកម្ម។

ដោយមើលឃើញមុខរបរកសិកម្មរបស់គាត់មានការរីកចម្រើន នៅឆ្នាំ២០១២ ពួកគាត់បានសម្រេចចិត្តចុះកិច្ចសន្យាជាមួយសហគ្រាសភូមិកសិកម្មធម្មជាតិ ដោយបានខ្ចីឥណទានពីសហគ្រាសនោះចំនួន ៤.០០០ ដុល្លារ ដើម្បីសាងសង់ផ្ទះសំណាញ់មួយបណ្តោយ ៣០ម ទទឹង១០ម និងកម្ពស់ ៣ម សម្រាប់ដាំបន្លែធម្មជាតិ។ តាមកិច្ចសន្យា អ្នកស្រី ពុតហៃ ត្រូវលក់បន្លែដែលគាត់ដាំបានទៅឱ្យ «ភូមិកសិកម្មធម្មជាតិ» ហើយដកប្រាក់ចំណេញមួយចំណែកបង់រំលួសរហូតទាល់តែគ្រប់តម្លៃផ្ទះសំណាញ់។

តាមរយៈការដាំដុះតាមបច្ចេកទេសថ្មី អ្នកស្រី ពុតហៃ អាចរកប្រាក់ចំណូលបាន ៥០០ដុល្លារក្នុងមួយខែ គឺកើនឡើងទ្វេដងបើធៀបទៅនឹងការដាំដុះតាមបែបបុរាណ។ ក្រោយកាត់ទូទាត់លើចំណាយផ្សេងៗ គាត់ចំណេញបាន ៣៥០ដុល្លារក្នុងមួយខែ ព្រមទាំងមានចំណូលបន្ថែមពីការលក់បន្លែរួមផ្សំប្រចាំថ្ងៃបាន ៣ដុល្លារថែមទៀតក្នុងមួយថ្ងៃ។ គិតត្រឹមខែ តុលា ឆ្នាំ២០២៣ អ្នកស្រី ពុតហៃ បានសងរំលស់ថ្លៃផ្ទះសំណាញ់ បានចំនួនសរុប ៧០០ដុល្លារហើយ។

នៅពេលដែលសុំឱ្យគាត់ធ្វើការវាយតម្លៃ



*បន្លែដែលអ្នកស្រី ពុតហៃ ដាំក្នុងផ្ទះសំណាញ់សាងសង់នៅលើដីចម្ការរបស់គាត់ស្ថិតក្នុងភូមិខ្សាច់ស ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។ អ្នកស្រី ពុតហៃ អាចរកប្រាក់ចំណូលពីការលក់បន្លែរបស់គាត់បានប្រហែល ៥០០ដុល្លារ ក្នុងមួយខែ។*

លើកម្រិតជីវភាពរស់នៅរបស់គ្រួសារគាត់នាពេលបច្ចុប្បន្ន អ្នកស្រី ពុតហៃ បានឆ្លើយតប ទាំងទឹកមុខញញឹមថា «បច្ចុប្បន្នស្ថានភាពសេដ្ឋកិច្ចគ្រួសាររបស់ខ្ញុំបានប្រសើរឡើង ៨០ភាគរយ បើប្រៀបធៀបកាលពី ១០ឆ្នាំ កន្លងទៅ។ កាលនោះ ពួកយើងទាំងពីរគ្មាន អ្វីសោះ។ ប៉ុន្តែ ឥឡូវនេះ ពួកយើងមានផ្ទះ មានចម្ការ ហើយមានលទ្ធភាពទិញអង្ករ ម្ហូបអាហារ និងថ្នាំសង្កូវសម្រាប់ព្យាបាលជំងឺនៅពេលឈឺស្កាត់ម្ដងៗ។»

អ្នកស្រី ពុតហៃ បានបន្តទៀតថា «ជីវភាព រស់នៅរបស់ពួក យើងបច្ចុប្បន្ននេះ ខុសប្លែកពីមុនឆ្ងាយណាស់។ ពីមុន ពេលចូលដេក មុននឹងបិទភ្នែក គិតថា ថ្ងៃស្អែកមិនដឹងបានអ្វីហូបទេ បើអង្ករក្នុងធុងជិតអស់ទៅហើយនោះ។» អ្នកស្រី បានបន្ថែម ទៀតថា «ឥឡូវ ពួកយើងមិនមានអារម្មណ៍បែបនេះទៀតទេ។ ឥឡូវ ពេលចូលដេក មុននឹងបិទភ្នែក ពួកយើងគិតអំពីផែនការការងារនៅព្រឹកស្អែក ថាតើត្រូវធ្វើអ្វីបន្ត និងត្រូវធ្វើអ្វីបង្ហើយ។»

អ្នកស្រី ពុតហៃ បានសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្ររបស់គម្រោង ដោយបានថ្លែងយ៉ាងដូច្នេះថា៖ «ពួកយើងសូមថ្លែងអំណរគុណដោយស្មោះចំពោះថ្នាក់ដឹកនាំគម្រោង ក៏ដូចជារាជរដ្ឋាភិបាល ដែលបានផ្ដល់ដីដល់គ្រួសារយើងខ្ញុំ។ វាដូចជាផ្ដល់នូវ ជីវិតថ្មីដល់ពួកយើងអញ្ចឹង។»

អ្នកស្រី ពុតហៃ មានកូនស្រីចំនួន ២ នាក់។ កូនច្បងអាយុ ១៤ឆ្នាំ និងកូនពៅអាយុ ៥ឆ្នាំ។ កូនស្រីច្បងកំពុងរៀនថ្នាក់ទី៦ នៅសាលារដ្ឋ និងរៀនភាសាអង់គ្លេសនៅសាលាឯកជន ដោយមានលទ្ធភាពបង់ថ្លៃសាលាក្នុងមួយខែ ២០ដុល្លារ ថែមទៀតផង៕



*អ្នកស្រីពុតហៃ លោក ដា និងកូនស្រីពៅ ឈរថតនៅខាងមុខផ្ទះទីពីរ ដែលបានសាងសង់នៅលើដីចម្ការរបស់គាត់កាលពីឆ្នាំមុន។*